ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០២០

## សេចក្តីផ្តើម

នៅក្នុងខែកុម្ភៈនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរដោយទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបាន៖

### ១- មុខងារនីតិកម្ម

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | - បានថតចម្លងឯកសារចំនួន១២៦ច្បាប់ អស់ក្រដាសចំនួន២,៩៨៣សន្លឹក<br>- បានសម្អាត តុបតែងសាល ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗសរុបចំនួន០១លើក មានអ្នកចូលរួមចំនួន២៥នាក់<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍មកពីខាងក្រៅស្ថាប័នចំនួន៣៥នាក់ ស្មើនឹង០១លើក<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១២លើក |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| | - បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញចំនួន ០១លើក ស្មើនឹង០១នាក់<br>- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗ ចំនួន៥៧៨ច្បាប់ និងបានចាត់ចែងតាមនីតិវិធី<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់ ពីរាជរដ្ឋាភិបាល និងបានចាត់ចែងតាមនីតិវិធី<br>- កំពុងសិក្សាផលិតឯកសារជំនួយស្មារតីលើ សេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់ (Legislative Notes)<br>- បានធ្វើបច្ចុប្បន្នភាពវេបសាយ( Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ ច្បាប់ដែលបានធ្វើវិសោធនកម្ម និងបានអនុម័តរួចៗ |

## ២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+ អញ្ជើញជួបសវនាការការងារជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីឈ្វេងយល់អំពីបញ្ហាប្រឈម និងសំណូមពរនានា<br>+ អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីសកម្មភាពគ្រប់គ្រងច្រកទ្វារព្រំដែន សកម្មភាពចេញ-ចូល របស់ប្រជាពលរដ្ឋកម្ពុជា និងបរទេសដែលឆ្លង | - បានធ្វើលិខិតបេសកកម្ម ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៨៣នាក់ ស្មើនឹង១០ច្បាប់<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្ត ក្រុងនានាចំនួន១២នាក់ ស្មើនឹង០៣លើក |

| | |
|---|---|
| កាត់ច្រកទ្វារព្រំដែន នៅខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តប៉ៃលិន<br>+ អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីការវិវត្តរីកចម្រើនថ្មី និងបញ្ហាប្រឈមរបស់ខេត្ត និងវិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង<br>+ អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីវិស័យជំនាញរបស់គណៈកម្មការ និងការគ្រប់គ្រងច្រកទ្វារព្រំដែនអន្តរជាតិ នៅខេត្តប៉ៃលិន និងខេត្តបន្ទាយមានជ័យ<br>+ អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីការផ្តល់សេវារដ្ឋបាល ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន មូលនិធិអភិវឌ្ឍន៍ឃុំសង្កាត់ និងអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពនៅខេត្តបន្ទាយមានជ័យ។ | - បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់សមាជិក សមាជិកាព្រឹទ្ធសភា បើកកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ និងជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ននានា ព្រមទាំងចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្ត ក្រុងនានា។ |

**៣- មុខងារតំណាង**

| វចនាសម្ព័ន្ធនយោបាយ | វចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា៖<br>+ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងព្រះរាជពិធីថ្វាយព្រះភ្លើង និងបូជាព្រះបរមសព សម្តេចព្រះធម្មលិខិត កិត្តិបណ្ឌិត លាស់ ឡាយ ថិរវិនយោ សម្តេចព្រះសង្ឃនាយករងទី១ ព្រះប្រធានថេរសភា នៃព្រះពុទ្ធសាសនា | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន អញ្ជើញជាគណៈ-អធិបតីក្នុងពិធីផ្លូវការនានា និងកិច្ចប្រជុំផ្សេងៗសរុបចំនួន១៨៣លើក<br>- បានចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០១លើក |

| | |
|---|---|
| នៅព្រះរាជាណាចក្រកម្ពុជា ព្រះអគ្គាធិការរងពុទ្ធិកសិក្សាជាតិ ឧត្តមសិក្សា ទីប្រឹក្សាជាតិភាសាខ្មែរ ព្រះអនុគណខណ្ឌមានជ័យ នាយកពុទ្ធិកអនុវិទ្យាល័យសន្សំកុសល និងជាព្រះចៅអធិការវត្តសន្សំកុសល នៅទីលានព្រះមេរុ ខាងមុខវត្តបទុមវតី រាជធានីភ្នំពេញ<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ជូនឯកឧត្តមអគ្គ-លេខាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ជាតិឡាវ និងជាប្រធានរដ្ឋនៃសាធារណរដ្ឋ-ប្រជាធិបតេយ្យប្រជាមានិតឡាវ និងគណៈប្រតិភូ<br>+ អញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរស្រុក មន្ត្រីរាជការកងកម្លាំង ព្រះសង្ឃ យាយជី តាជី ប្រជា-ពលរដ្ឋ និងពិនិត្យមើលសមិទ្ធផលនានាក្នុងវត្ត នៅរាជធានីភ្នំពេញ និងខេត្តតាកែវ ព្រមទាំងសាកសួរសុខទុក្ខអតីតយុទ្ធជនយុវនារីភូមិភាគឦសាន ដែលមានជំងឺ និងកំពុងព្យាបាលវះកាត់នៅមន្ទីរពេទ្យកាល់ម៉ែត្រ<br>+ អញ្ជើញជាអធិបតី និងថ្លែងសុន្ទរកថាក្នុងពិធីពិសាអាហារសាមគ្គីទទួលស្វាគមន៍គណៈប្រតិភូជាន់ខ្ពស់គណៈកម្មាធិការមជ្ឈិមរណសិរ្សអភិវឌ្ឍន៍ជាតិឡាវ ដឹកនាំដោយឯកឧត្តម **ខាំបៃ ដាំឡាត់** សមាជិក | - បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៦៥ច្បាប់ ស្មើនឹង២៨១នាក់<br>- បានថតចម្លងឯកសារចំនួន៨៧២ច្បាប់ អស់ក្រដាសចំនួន៣,៦៧០សន្លឹក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៣០លើក ស្មើនឹង១៥៨នាក់<br>- បានទទួលលិខិតចូលចំនួន៩៦០ច្បាប់ និងបញ្ជូនលិខិតចេញចំនួន២៩៣ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន៥៨លើក ស្មើនឹង១១៩នាក់<br>- បានផ្តល់អត្ថបទព័ត៌មាន និងរូបភាពស្តីពីសកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញសង្គមព្រឹទ្ធសភាចំនួន៣៧លើក<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធា-រណជន ចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភាចំនួន១៥០នាក់ អនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន៣៨ក្បាល និងសងវិញចំនួន៨៨ក្បាល<br>- បានផ្តល់សៀវភៅជូនមន្ត្រីរាជការនៃអគ្គលេខា- |

| | |
|---|---|
| មជ្ឈិមបក្សប្រជាជនបដិវត្តន៍ជាតិឡាវ និងជាអនុប្រធានគណៈកម្មាធិការមជ្ឈិមរណសិរ្សអភិវឌ្ឍន៍ជាតិឡាវ នៅខេត្តស្ទឹងត្រែង<br>+ អញ្ជើញចូលរួមពិធីរាប់បាត្រព្រះសង្ឃ៧២អង្គ និងចែកអំណោយជូនយាយជីតាជី នៅវត្តប្រាំបីមុំ នៅខេត្តតាកែវ<br>+ អញ្ជើញពិសាអាហារសាមគ្គីជាមួយក្រុមសមាជិកាព្រឹទ្ធសភា នៅភោជនីយដ្ឋានបាណាណាលីវ<br>+ អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីសាធារណរដ្ឋបារាំង ទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកណ្តាល ព្រមទាំងចាត់ឱ្យក្រុមការងារបញ្ជូនអ្នកជំងឺឈឺធ្ងន់០១រូប ទៅពិនិត្យ និងព្យាបាលនៅមន្ទីរពេទ្យដោវៃភ្នំពេញ<br>- ក្រុមសមាជិក សមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានធ្វើវេទិកាថ្នាក់ស្រុកចំនួន០១លើក ស្តីពី ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងសហការផ្តល់សេវាសាធារណៈ ព្រមទាំងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តកំពង់ចាម<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន០៦ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន០៩ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០១ករណី កំពុងពិនិត្យសិក្សាចំនួន០៤ករណី ព្រមទាំងទទួលឯកសារពាក្យបណ្តឹងដែល | ធិការដ្ឋានព្រឹទ្ធសភាចំនួន៨០ក្បាល<br>- បានផលិតទស្សនាវដ្តីប្រចាំខែកុម្ភៈ ឆ្នាំ២០២០ ចំនួន១,២០០ក្បាល<br>- បានផលិតវីដេអូសមិទ្ធផលការងារ២ឆ្នាំរបស់គណៈកម្មការទី៨ ព្រឹទ្ធសភា (ឆ្នាំ២០១៨-២០១៩)<br>- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភាចំនួន០៧លើក<br>- បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សារបស់មន្ត្រីទីចាត់ការការងារព្រំដែនអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទចំនួន២៧នាក់។ |

| | |
|---|---|
| ក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈ-កម្មការដើម្បីជូនជ្រាបចំនួន០៦ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ទូទាំងប្រទេសចំនួន១០០លើក ដើម្បីជួបពិភាក្សាការងារ ជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការផ្សេងៗ សរុបចំនួន៦៩លើក។ | |

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានអនុញ្ញាតឱ្យប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសអូស្ត្រាលី ប្រចាំនៅព្រះរាជាណា- | - អគ្គលេខាធិការព្រឹទ្ធសភា បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI)<br>- បានរៀបចំទីកន្លែងជូនថ្នាក់ដឹកនាំព្រឹទ្ធសភា |

| | |
|---|---|
| ចក្រកម្ពុជា, ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋគុយបាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការ និងសម្តែងការគួរសម<br>- **ឯកឧត្តម ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា** បានអញ្ជើញជាអធិបតីក្នុងសន្និសីទអន្តរជាតិលើកទី២ ស្តីពី ការកសាងខ្សែបន្ទាត់ព្រំដែនសន្តិភាព មិត្តភាព និងសហប្រតិបត្តិការល្អ រវាងរណសិរ្សប្រទេសទាំងពីរ កម្ពុជា-ឡាវ នៅខេត្តស្ទឹងត្រែង។ | ក្នុងជំនួបសវនាការ និងសម្តែងការគួរសមជាមួយភ្ញៀវអន្តរជាតិចំនួន០៣លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា ជួបជាមួយភ្ញៀវជាតិ និងអន្តរជាតិ ដែលមកបំពេញទស្សនកិច្ចនៅព្រឹទ្ធសភាចំនួន០៤លើក<br>- បានថតចម្លងឯកសារចំនួន៣០៥ច្បាប់ អស់ក្រដាសចំនួន១,៤១១សន្លឹក<br>- បានរៀបចំសម្អាត តុបតែងលម្អសាល ផ្គត់ផ្គង់សម្ភារប្រើប្រាស់ និងបម្រើសេវាភេសជ្ជៈ ក្នុងកិច្ចប្រជុំចំនួន១២លើក មានអ្នកចូលរួមចំនួន១០៩នាក់<br>- បានធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត លិខិតឆ្លើយតប និងឯកសារជំនួយស្មារតីពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចសង្គម សភាប្រទេសជាដៃគូ និងលិខិតផ្សេងៗជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងគណៈប្រតិភូនានារបស់ព្រឹទ្ធសភាចំនួន៣៤លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៨នាក់ ស្មើនឹង០៣ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១៧លើក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ |

| | |
|---|---|
| | នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន០៤លើក ស្មើនឹង០៩នាក់<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១១លើក ស្មើនឹង២៥នាក់<br>- បានផលិតវីដេអូព័ត៌មានស្តីពី ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបជាមួយភ្ញៀវជាតិ និងអន្តរជាតិចំនួន០៤លើក។ |

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | - បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៤០ច្បាប់<br>- ប្រជុំជាមួយតំណាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រដ្ឋសភា និងក្រុមប្រឹក្សាធម្មនុញ្ញពាក់ព័ន្ធនឹងផលប្រយោជន៍មន្ត្រីរាជការ៣ស្ថាប័ន<br>- ប្រជុំក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានសភាកម្ពុជា(PIC) ដើម្បីកំណត់ផែនការសកម្មភាព និងថវិកាអនុវត្តឆ្នាំ២០២០ ព្រមទាំងផែនការ PCA ក្នុងឆ្នាំ២០២០<br>- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី សកម្មភាពការងារព្រឹទ្ធសភា និងអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាប្រចាំខែកុម្ភៈ ឆ្នាំ២០២០ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រសួង និងស្ថាប័ននានា។<br>- **ការងារគ្រប់គ្រងបុគ្គលិកៈ**<br>+ បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន២២៧ច្បាប់ |

| | |
|---|---|
| | + បានសិក្សាកែសម្រួល និងធ្វើបច្ចុប្បន្នភាព គោលការណ៍ស្តីពី ការតែងតាំងមន្ត្រីរាជការ ឱ្យកាន់មុខតំណែងក្នុងអង្គការលេខនៃរចនាសម្ព័ន្ធ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>+ បានប្រជុំវាយតម្លៃតម្លើងថ្នាក់បៀវត្សមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមវេនជ្រើសរើស និងតាមវេនអតីតភាព សម្រាប់ឆ្នាំ២០២០<br>+ បានធ្វើបែបបទស្នើសុំគ្រឿងឥស្សរិយយសជូន មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>+ បានធ្វើបញ្ជីសោធននិវត្តន៍ និងសោធនបាត់បង់ សម្បទាវិជ្ជាជីវៈប្រចាំខែរបស់និវត្តជន និងបានកែប្រែតម្លៃឯកតាសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>+ បានរៀបចំរចនាសម្ព័ន្ធ គោលការណ៍ និងគោលនយោបាយថ្មីៗ<br>+ បានបោះពុម្ពលិខិតសុំច្បាប់ និងការអនុញ្ញាតច្បាប់ ឈប់សម្រាកគ្រប់ប្រភេទរបស់មន្ត្រីរាជការនៃ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០២០ ចំនួន២២,៥០០ច្បាប់ ព្រមទាំងបានចែកជូន អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣,០០០ច្បាប់។<br>- **ការងារបណ្តុះបណ្តាលធនធានមនុស្ស៖**<br>+ បានបើកវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស ចំនួន០៤វគ្គ មានសិក្ខាកាមចូលរួមចំនួន១០០នាក់<br>+ បានធ្វើបច្ចុប្បន្នភាពសម្រង់ស្ថិតិតម្រូវការ បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។ |

| | |
|---|---|
| | - ***ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖***<br>+ បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>+ អនុវត្តការងារលទ្ធកម្មសាធារណៈឆ្នាំ២០២០ និងការចាប់ផ្តើមកាត់ឯកសណ្ឋានជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>+ បានរៀបចំតភ្ជាប់បណ្តាញប្រព័ន្ធ (FMIS) និងការប្រើប្រាស់<br>+ បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំសិក្ខាសាលាផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៧០សំណើ<br>+ បានរៀបចំសម្អាត តុបតែងសាលប្រជុំ ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន ១៩លើក មានអ្នកចូលរួមចំនួន៦៦០នាក់<br>+ បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៣២៤លើក<br>+ បានថតចម្លងឯកសារចំនួន៣,៤៧៩ច្បាប់ ចងក្រងធ្វើជាសៀវភៅចំនួន៧៦ក្បាល អស់ក្រដាសចំនួន២២,៣៥៨សន្លឹក ព្រមទាំងបានជួសជុលសម្អាតម៉ាស៊ីនថតចម្លង និងម៉ាស៊ីនព្រីនធ័រចំនួន ០៨លើក |

| | |
|---|---|
| | + បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន៩២លើក ស្មើនឹង១៣៩នាក់<br>+ បានជួសជុលរថយន្ត ព្រមទាំងទិញសម្ភារផ្សេងៗសម្រាប់បំពាក់រថយន្តចំនួន០៩លើក។<br>- **ការកសាង អភិវឌ្ឍន៍ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ៖**<br>+ រៀបចំស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤<br>+ បានបើកការដ្ឋានសាងសង់អគារ១ខ្នង កម្ពស់២ជាន់ នៅខាងក្រោយអគារមូលនិធិខ្មែរអភិវឌ្ឍន៍<br>+ បានសង់រោងដែកប្រក់ដំបូលការបូណាតនៅខាងក្រោយសាលពិសេស<br>+ បានជួសជុលកែលម្អ ខាត់ និងលាបនៅអគារក្រហម អគារDEF អគារជប៉ុន សាលពិសេសធំ និងបន្ទប់ប្រធាននាយកដ្ឋានស្រាវជ្រាវច្បាប់<br>+ បានកែលម្អសួនច្បារ និងបានរៀបចំដាំដើមឈើថ្មីក្នុងបរិវេណព្រឹទ្ធសភាចំនួន០៣លើក ស្មើនឹង០៦ប្លង់<br>+ បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារបណ្តាញទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិក គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៦៤គ្រឿង/លើក |

| | |
|---|---|
| | + បានសហការជាមួយក្រុមហ៊ុន Maintenances ត្រួតពិនិត្យជណ្តើរយន្តចំនួន០២លើក<br>+ បានសហការជាមួយក្រុមហ៊ុនកម្ចាត់សត្វកណ្តៀរ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ ព្រមទាំងបានត្រួតពិនិត្យការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន ៣៤លើក<br>+ បានបង្កើត Email, Telegram ជាមធ្យោបាយ សម្រាប់ទទួល និងបញ្ជូនឯកសារ ជូនសមាជិក សមាជិកាព្រឹទ្ធសភា<br>+ បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Connect Wifi និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និង Set up កម្មវិធីសរុបចំនួន៨៦គ្រឿង។<br>- **ការងារផ្សេងៗ៖**<br>+ បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព និង ចងបដា ពាក្យស្លោក និងចងទង់ជាតិចំនួន១៣លើក<br>+ បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាព ការងាររបស់ព្រឹទ្ធសភាចំនួន៥៥លើក<br>+ បានផលិតវីដេអូព័ត៌មានកម្មវិធីផ្សេងៗរបស់ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៦លើក<br>+ បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយ ព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៥៣លើក<br>+ បានទទួល និងរៀបចំសៀវភៅច្បាប់ ឯកសារ រាជកិច្ច និងទស្សនាវដ្តីចំនួន១០៩ក្បាល ព្រមទាំង បានបោះត្រា ចុះបញ្ជីសៀវភៅ បិទប័ណ្ណខ្ទី និង សងសៀវភៅ អ៊ុតក្របសៀវភៅ និងបញ្ចូលសៀវភៅ |

| | |
|---|---|
| | ភាសាអង់គ្លេសក្នុងកម្មវិធីKOHAចំនួន២៣២ក្បាល<br>+ បានបញ្ចូលឯកសារ សៀវភៅច្បាប់ សៀវភៅបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនាញផ្សេងៗតាម E-Library & NAS ចំនួន ១២៧ក្បាល។ |

## II-**ទិសដៅការងារសម្រាប់ខែមីនា ឆ្នាំ២០២០**

### ១- **មុខងារនីតិកម្ម**

-ព្រឹទ្ធសភាវិស្សមកាលពីថ្ងៃទី២៣ ខែមករា ដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០

-ខុទ្ទកាល័យថ្នាក់ដឹកនាំទាំង៣ លេខាធិការដ្ឋានអមគណៈកម្មការទាំង១០ និងអង្គភាពពាក់ព័ន្ធត្រៀមផ្តល់របាយការណ៍ចន្លោះសម័យប្រជុំព្រឹទ្ធសភាលើកទី៤ និងលើកទី៥នីតិកាលទី៤ ឱ្យបានទាន់ពេលវេលា

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១- សេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

៣-គម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម ២៦៥មេហ្គាវ៉ាត់ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ គម្រោងអភិវឌ្ឍបណ្តាញបញ្ជូន២៣០គីឡូវ៉ុល ពីរោងចក្រអគ្គិសនីធ្យូងថ្មឧត្តរមានជ័យមកអនុស្ថានីយសៀមរាប និងគម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម៧០០មេហ្គាវ៉ាត់ នៅស្រុកបុទុមសាគរ ខេត្តកោះកុង និងការអនុវត្តបន្តទៀត

៤-បញ្ហាផ្សេងៗ សំណើសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើ៖

៤.១-សន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមក ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

៤.២-សន្ធិសញ្ញាស្តីពី ការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

៤.៣-ពិធីសារទីមួយ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន

៤.៤-ពិធីសារទីពីរ ស្តីពី វិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

៤.៥-ពិធីសារទីបី ស្តីពី វិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនគណៈកម្មការជំនាញ ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗ និងការចុះបេសកកម្មទៅខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ សៀមរាប កំពង់ធំ ពោធិ៍សាត់ កណ្តាល កំពង់ស្ពឺ និងខេត្តព្រះសីហនុ។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្លូវការនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមប្រារព្ធទិវាអន្តជាតិនារី ៨មីនា និងពិធីអបអរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំ២០២០

-ត្រៀមរៀបចំពិធីបុណ្យបញ្ចុះខណ្ឌសីមាវត្ត នៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូជាតិ/អន្តរជាតិ និងអង្គទូតនានា (ទូតប្រទេសអ៊ីស្រាអែល)

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទៅបំពេញបេសកកម្មក្រៅប្រទេស

-ត្រៀមចូលរួមមហាសន្និបាតលើកទី១៤៣ របស់សហភាពអន្តរសភា (IPU) នាថ្ងៃទី១៣-២០ ខែមេសា ឆ្នាំ២០២០

-ត្រៀមចូលរួមជាមួយរដ្ឋសភា ដើម្បីរៀបចំ ASEP/ASEM ឆ្នាំ២០២០

-ត្រៀមរៀបចំទិវាហ្វ្រង់កូហ្វូនីប្រចាំឆ្នាំ (ខួបលើកទី៥០) នៅព្រឹទ្ធសភា នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅក្នុងបរិវេណព្រឹទ្ធសភា

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិក តាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះចូលរួមអនុវត្តកម្មវិធី Eបណ្ណាល័យ និង E បណ្ណសារ

-បន្តប្រជុំគណៈកម្មការគោលការណ៍ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ត្រៀមប្រជុំវាយតម្លៃផែនការប្រតិបត្តិគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី១ ឆ្នាំ២០២០

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀត ឆ្នាំ២០២០

-ត្រៀមរៀបចំផែនការបណ្តុះបណ្តាលមន្ត្រីខ្សោយ និងពិបាកដោយផ្សារភ្ជាប់វិធានការអប់រំ រដ្ឋបាល ច្បាប់ និងអភិក្រមទាំង៥

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT) គ្រប់វិស័យនៃការងាររបស់ស្ថាប័ន

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) អភិវឌ្ឍធនធានមនុស្ស ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ការស្រាវជ្រាវ និងសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការដាក់ស្តែង

-បន្តរៀបចំក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងរយៈពេល១០ឆ្នាំទៅមុខ (ឆ្នាំ២០២១-២០៣០)

-បន្តសហការជាមួយក្រុមការងារ FMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់ ប្រព័ន្ធFMIS។

## III-**សេចក្តីសន្និដ្ឋាន**

ខែកុម្ភៈនេះ ព្រឹទ្ធសភាស្ថិតក្នុងអំឡុងពេលវិស្សមកាល។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ជាអាទិភាពលើមុខងារតាមដានការអនុវត្តច្បាប់ ដោយបានផ្តល់សេវាជូនគណកម្មការជំនាញទាំង១០ ចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា និងជួបសន្ទនាការការងារជាមួយក្រសួងផ្សេងៗ បានយ៉ាងល្អប្រសើរ។ ចំពោះមុខងារតំណាង បានដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ និងរៀបចំវេទិកា ព្រមទាំងអមដំណើរសមាជិកព្រឹទ្ធសភាចុះតាមមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋ។ ចំពោះការអភិវឌ្ឍស្ថាប័ន បានខិតខំកែសម្រួលរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

ឱ្យបានកាន់តែសមស្របតាមបរិបទថ្មីបន្ថែមទៀត។ ទន្ទឹមនឹងនេះ ការបង្កើនសមត្ថភាពស្រាវជ្រាវការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) ក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងខិតខំជំរុញការផ្តល់សេវាឱ្យបានគាប់ប្រសើរ ហើយបន្តខិតខំកែលម្អសេវាទាំងឡាយឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT) ជាអតិបរមា ដើម្បីកាត់បន្ថយការប្រើប្រាស់ក្រដាស។ ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិព្រឹទ្ធសភាបានចូលរួមអនុវត្តគោលនយោបាយពង្រឹងទំនាក់ទំនងខាងក្នុង និងពង្រីកទំនាក់ទំនងខាងក្រៅ ដើម្បីបង្កើនជំនឿទុកចិត្តឱ្យបានខ្ពស់ពីសំណាក់ដៃគូទាំងអស់របស់ព្រឹទ្ធសភា ក្នុងន័យបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែប្រកបដោយផ្លែផ្កាថែមទៀត។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០
**អគ្គលេខាធិការស្តីទី**

ឡោក_ឆាយ